រាជបណ្ឌិត្យសភាកម្ពុជា

# ការសិតបដិមាទោលព្រះនាងឥន្ទ្រទេវី



ស្រាវជ្រាវនិងចងក្រងដោយៈ

**យង់ ពៅ, ផុន កសិកា, ម៉ិល វាសនា, តាកេត ស័កដា, ហឿង សុធារស់, ប្រែប ពិសិដ្ឋ**

ខែមករា ឆ្នាំ២០២០

# ការសិតបដិមាទោលព្រះនាងឥន្ទ្រទេវី

បដិមាទោលព្រះនាងឥន្ទ្រទេវីត្រូវបានកសាងឡើងជាលើកដំបូងបំផុតនៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា ធ្វើឡើងដោយហ្មត់ចត់តាមលក្ខណៈវិទ្យាសាស្ត្រនិងប្រកបដោយជំនាញវិជ្ជាជីវៈ។ មុននឹងឈានដល់ការសិតបដិមាទោលនេះឡើង មានក្រុមស្រាវជ្រាវចុះសិក្សាផ្ទៀងផ្ទាត់រូបចម្លាក់ព្រះនាងឥន្ទ្រទេវី មានការរៀបចំសិក្ខាសាលា តុមូល ដោយប្រមូលផ្តុំអ្នកស្រាវជ្រាវនិងអ្នកជំនាញទាំងជាតិនិងអន្តរជាតិ មកពីស្ថាប័នផ្សេងៗមកធ្វើបទបង្ហាញនិងជជែកពិភាក្សា ឈានទៅដល់ការឯកភាពគ្នាលើអត្តសញ្ញាណព្រះនាងឥន្ទ្រទេវីសម្រាប់ការកសាងជាបដិមាទោលរបស់ព្រះនាងឡើង។ លើសពីនេះទៀត ដោយសាររូបចម្លាក់ដែលកំណត់ដោយអង្គសិក្ខាសាលា ជារូបនៅជាប់នឹងជញ្ជាំង នោះទម្រង់លក្ខណៈនិងក្បាច់ផ្សេងៗនៃរូបនៅផ្នែកខាងក្រោយបានក្លាយជាចំណោទបញ្ហាដ៏សំខាន់មួយទៀតសម្រាប់ការសិក្សាស្រាវជ្រាវ។ ជាកិច្ចការបន្ត ក្រុមស្រាវជ្រាវនិងជំនាញស្ទូនបានចុះសិក្សាផ្ទៀងផ្ទាត់លើរូបបដិមាទោល សិតអំពីស្ពាន់ក្នុងរចនាប័ទ្មសម័យកាលជាមួយគ្នា និងមានទម្រង់ប្រហាក់ប្រហែលគ្នានៅសារមន្ទីរជាតិភ្នំពេញ ដើម្បីសូននិងឆ្លាក់ចម្លងទម្រង់ផ្នែកខាងក្រោយ។ ការចម្លងរូបភាពតាមនៅផ្នែកខាងក្រោយនេះ គេពិនិត្យទៅលើកត្តាមួយចំនួនដូចជា ទម្រង់អែននៃរូប កម្រិតនៃភាពដូចទម្រង់អែនទៅនឹងទម្រង់មនុស្សពិត ផ្នែកខាងក្រោយនៃមុក្ដាហារ(ខ្សែក) ផ្នែកខាងក្រោយនៃខ្សែក្រវាត់ និង ផ្នែកខាងក្រោយនៃសំពត់ ជាដើម។

អត្ថបទនេះ ផ្តោតសំខាន់លើដំណើរការកសាងបដិមាទោលព្រះនាងឥន្ទ្រទេវីទៅតាមដំណាក់កាលជាបន្តបន្ទាប់រហូតបានបដិមាទោលសម្រេច ព្រមទាំងពិពណ៌នាពីគ្រឿងតុបតែងលម្អផ្សេងៗរបស់ចម្លាក់បដិមាផងដែរ ។

## ដំណើរការកសាងបដិមាទោលព្រះនាងឥន្ទ្រទេវី

ការកសាងបដិមាទោលព្រះនាងឥន្ទ្រទេវីជាលើកដំបូងក្នុងប្រវត្តិសាស្ត្រនេះ គឺសិតអំពីស្ពាន់ មានទំហំធំជាងរូបចម្លាក់ដើមនៅជាប់ជញ្ជាំងនៃប្រាសាទព្រះខ័ន ដោយមានកម្ពស់១,៩៧ម៉ែត្រ (គិតពីព្រះបាទដល់ព្រះសិរ) និង មានទំហំដងខ្លួនសមាមាត្រទៅនឹងរូបចម្លាក់ដើមនៅជញ្ជាំងប្រាសាទព្រះខ័ន។ ការសិតបដិមានេះគឺទទួលបានជំនួយឧបត្ថម្ភពីលោកជំទាវឧកញ៉ាកិត្តិបណ្ឌិត សៀង ចាន់ហេង អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ដែលចំណាយថវិកាអស់ចំនួន ១២៦០០$ (ដប់ពីរពាន់ប្រាំមួយរយដុល្លារអាម៉េរិក)។

ដំណើរការសិតបដិមាព្រះនាងឥន្ទ្រទេវីប្រព្រឹត្តទៅច្រើនដំណាក់កាលៈ ដំណាក់កាលសូនឬប៉ាន់រូបពីដីឥដ្ឋ, ដំណាក់កាលធ្វើពុម្ពចម្លង, ដំណាក់កាលធ្វើបដិមាក្រមួននិងធ្វើពុម្ពដុត, ដំណាក់កាលដុតពុម្ព, ដំណាក់កាលសិតបដិមា និង ដំណាក់កាលផ្តុំនិងលាបពណ៌សម្រេច។

### ១- ដំណាក់កាលសូនឬប៉ាន់រូបពីដីឥដ្ឋ

នៅក្នុងដំណាក់កាលនេះ ស្ទូនត្រូវចាប់ផ្តើមដោយការរៀបចំគ្រោងឆ្អឹងដែកតាមរូបរាងបដិមា រួចយកដីឥដ្ឋសូនឬប៉ាន់ (យកដីឥដ្ឋបិទបៀកលើគ្រោងឆ្អឹងដែក) ជារូបឱ្យដូចទៅនឹងបដិមាដែលបានកំណត់។ ស្ទូនត្រូវឆ្លាក់រូបនិងចិតក្បាច់យ៉ាងយកចិត្តទុកដាក់បំផុតដើម្បីជៀសវាងការលម្អៀងពីរូបចម្លាក់ដើម។



*បដិមាសូនឬប៉ាន់ពីដីឥដ្ឋ*

### ២- ដំណាក់កាលធ្វើពុម្ពចម្លង

*នៅដំណាក់កាលនេះ ស្មូនធ្វើពុម្ពចម្លងពីរូបដីឥដ្ឋដោយយកស៊ីលីកូន [1] បៀកបិទឱ្យសព្វលើរូបចម្លាក់ដីឥដ្ឋនោះ។ ដោយស៊ីលីកូនមានសភាពទន់ស្អិត វាអាចជ្រាបចូលសព្វកន្ទុកកន្ទៀតនៃក្បាច់ចម្លាក់បានល្អ។ នៅកំលុងពេលជាមួយគ្នានោះ ស្មូនបានកំណត់ខ័នផ្ដាច់ពុម្ពស៊ីលីកូនជា៥ផ្នែកធំៗ ដើម្បីសម្រួលដល់ការផ្សារសិតបដិមា។ ស្មូនបានប្រើបន្ទះស័ង្កសីស្ដើងសៀតនៅតាមទីកន្លែងដែលកំណត់ខ័នផ្ដាច់ពុម្ពទាំង៥ផ្នែកនោះ។ ផ្នែកទាំង ៥នោះមាន ទី១៖ ពីកំពូលមកុដដល់ចង្កេះ, ទី២៖ ផ្នែកដៃខាងស្ដាំ, ទី៣៖ ផ្នែកដៃខាងឆ្វេង, ទី៤៖ ពីចង្កេះសំពត់ដល់ជាយសំពត់ខាងក្រោម និង ទី៥៖ ប្រអប់ជើងនិងជើងទម្រ។ បន្ថែមពីលើនេះ កម្រងផ្កា និងផ្កាឈូកត្រូវធ្វើពុម្ពដោយឡែកផ្សេងទៀត។*

*បន្ទាប់មក ស្មូនស្មាច់លើពុម្ពស៊ីលីកូននោះមួយជាន់បន្ថែមទៀត ដើម្បីជាវត្ថុធាតុរឹងអាចទប់ពីខាងក្រៅពុម្ពស៊ីលីកូនដែលមានសភាពទន់។ បន្ទាប់ពីស្មាច់កករឹង ស្មូនចោះស្មាច់នោះជាច្រើនរន្ធជុំវិញពុម្ព ដើម្បីចាប់ប៊ូឡុងមុនពេលបកពុម្ព។ ក្រោយពេលបកពុម្ព គេបានពុម្ពចម្លងមួយដែលមានរូបរាងនិងក្បាច់ចម្លាក់ដូចគ្នានឹងរូបសូនពីដីឥដ្ឋនោះ។*

---

[1] *ស៊ីលីកូនជាសារធាតុរាវ ស្អិត ហើយការធ្វើពុម្ពស៊ីលីកូននេះគឺគេត្រូវយកវាកូររើកលាយជាមួយទឹករឹងតាមកម្រិតខ្នាត រួចទើបយកវាមកបៀកបិទលើរូបដែលសូនអំពីដីឥដ្ឋ។*



*ការប៉ាន់ស៊ីលីកូនលើរូបសូនដីឥដ្ឋដើម្បីចម្លងពុម្ព ដោយមានបន្ទះស័ង្កសីស្តើងសៀតខ័នផ្តាច់ពុម្ពជាផ្នែកៗ*

### ៣- ដំណាក់កាលធ្វើបដិមាក្រមួននិងធ្វើពុម្ពដុត

*នៅពេលបកពុម្ពចម្លងស៊ីលីកូន ស្មូនត្រូវសម្អាតពុម្ពនេះ (វាអាចមានជាប់ដីឬមិនស្អាត) មុនពេលស្មូនយកក្រមួនដែលគេបានដុតឱ្យរលាយមកចាក់ក្នុងពុម្ពចម្លងស៊ីលីកូនទាំងពីរខាង (ផ្នែកមុខ និង ផ្នែកក្រោយ) ហើយយកដក់មកបោសលាបឱ្យជ្រាបចូលសព្វសាច់តាមកន្ទុកកន្ទៀតក្បាច់ទាំងអស់ក្នុងកម្រាស់ ២ហ៊ុនស្មើ រួចទើបគេចាប់ប៊ូឡុងផ្គុំពុម្ពចម្លងនោះបញ្ចូលគ្នាឡើងវិញ (ពុម្ពផ្នែកខាងមុខនិងផ្នែកខាងក្រោយ) ឱ្យជិតណែនជាប់គ្នា បន្ទាប់ពីក្រមួននោះស្ងួតរឹង។ សូមបញ្ជាក់ថា នៅពេលគេផ្គុំពុម្ពចម្លងបញ្ចូលគ្នាវិញ គឺពុម្ពនេះប្រហោងនៅផ្នែកខាងក្នុងដោយសារវាមានតែក្រមួននៅជាប់នឹងពុម្ពនោះប៉ុណ្ណោះ។*

*បន្ទាប់មក គេចាក់ម្នាងសិលាលាយខ្សាច់ឱ្យចូលណែនបំពេញប្រហោងពុម្ពនៅផ្នែកតូចៗដូចជា នៅផ្នែកព្រះសិរ ផ្នែកដៃទាំងពីរខាង និង ប្រអប់ជើងនៅលើទម្រ ជាដើម ដើម្បីជាស្នូលសម្រាប់ទប់គាបក្រមួនឱ្យហាប់ណែននឹងពុម្ពស៊ីលីកូន។ ដោយឡែក ចំពោះផ្នែកពុម្ពដែលមានប្រហោងធំដូចជា ផ្នែកដងខ្លួន ផ្នែកសំពត់ និង ផ្នែកជើងទម្រជាដើម គេពុំចាក់ម្នាងសិលាលាយខ្សាច់ឱ្យពេញណែនប្រហោងទាំងស្រុងដូចនៅផ្នែកតូចៗទេ [2] តែគេចាក់បំពេញខ្លះនិងទុកខ្លះសម្រាប់បៀកបូកលើក្រមួននោះ ដើម្បីជៀសវាងពុម្ពទាំងនោះធ្ងន់ពេក។*

*បន្ទាប់ពីចាក់បៀកបូកម្នាងសិលារួចរាល់និងទុករយៈពេលប្រមាណជា ៣០នាទី ដើម្បីឱ្យម្នាងសិលារឹងស្ងួតហើយ គេដោះប៊ូឡុងបកពុម្ពស្នាច់និងស៊ីលីកូនចេញ ដើម្បីបានបដិមាក្រមួនដែលមានស្នូលខាងក្នុងជាម្នាងសិលា។ នៅពេលបានបដិមាក្រមួនហើយ ស្មូនត្រូវពិនិត្យមើលលើបដិមាក្រមួននេះបន្ថែមទៀត ដើម្បីសម្អាតនិងចិតក្បាច់*

---

[2] *ព្រាប សោភ័ណ ស្ថាបត្យករអគារឥន្ទ្រទេវីនិងជាអ្នកជំនាញសំណង់បុរាណ ។ (សម្ភាសថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩)*

បន្ថែមនៅចំណុចខ្វះខាតទាំងឡាយ។ បន្ទាប់ពីបានពិនិត្យកែលម្អហើយ គេបណ្ដុះឈ្នុលក្រមួនមួយចំនួន (ក្រមួនតាន់មូលៗប៉ុនកដៃ ភ្ជាប់ពីបដិមាក្រមួនឡើងលើ) លើបដិមាក្រមួនសម្រាប់ជារន្ធផើយសិតស្ពាន់។



*សកម្មភាពស្ទូនបកពុម្ពស៊ីលីកូនឱ្យបានចេញជាបដិមាក្រមួន*



*ស្ទូនសម្អាតនិងចិតក្បាច់បន្ថែមលើបដិមាក្រមួន*



*ស្ទូនសម្អាតនិងចិតក្បាច់បន្ថែមលើបដិមាក្រមួន*

បន្ទាប់ពីបណ្ដុះឈ្នុលក្រមួនរួចហើយ គេយកម្នាងសិលាលាយជាមួយខ្សាច់មកបៀកបិទលើបដិមាក្រមួនដើម្បីជាផ្នែករឹងទប់បដិមាក្រមួននោះ។ ប៉ុន្តែគេមិនបិទផ្នែកខាងលើឈ្នុលទេ ដោយគេរក្សាទុកជាផើយសម្រាប់សិតស្ពាន់ ឬសម្រាប់បង្ហូរក្រមួនចេញ។ នៅពេលម្នាងសិលានេះស្ងួត គេធ្វើឆ្អឹងដែកគ្រីបព័ទ្ធជុំវិញរូបនេះបន្ថែមទៀតដើម្បីការពារនៅពេលសិតស្ពាន់ចូលពុម្ពប្រេរីកមាឌដែលអាចធ្វើឱ្យរហែក ឬហៀរស្ពាន់ចេញមកក្រៅ។ បន្ថែមលើនេះ គេប៉ាតដីឥដ្ឋលាយជាមួយអង្កាមមួយជាន់ទៀតលើម្នាងសិលាគ្រីបដែកនេះ ដើម្បីធ្វើឱ្យវាកាន់តែមានលក្ខណៈរឹងមាំនិងដុតពុម្ពធំកម្ដៅបានល្អ។ ក្រោយពេលបិទដីលាយអង្កាមរួចហើយ គេរក្សាទុកវាប្រមាណពីរថ្ងៃដើម្បីឱ្យស្ងួតមុននឹងដុតពុម្ព ។



ការបណ្តុះឈ្នុល (ពណ៌ខ្មៅ) លើពុម្ពបដិមាក្រមួន



ការបិទប៉ាតម្នាងសិលាពីលើបដិមាក្រមួន



ជាងស្មិតបិទប៉ាតម្នាងសិលាពីលើជើងទម្រ



សកម្មភាពគ្រីបឆ្អឹងដែកលើម្នាងសិលា



ការបិទម្នាងសិលាលើដែកគ្រីបផ្នែកកំណាត់ខាងក្រោម



ការបិទដីអង្កាមផ្នែកខាងក្នុងដើម្បីឱ្យកម្ដៅធំល្អនៅពេលដុត



*រូបភាពពុម្ពផ្នែកសំពត់និងផ្នែកជើងទម្រក្រោយប៉ាតបិទដីលាយអង្កាម និង រន្ធផើយនៃឈ្នុល*

### ៤- ដំណាក់កាលដុតពុម្ព

*ការដុតពុម្ពសំដៅដល់ការដុតពុម្ពដែលបានប៉ាតបិទដីលាយអង្កាម ដើម្បីឱ្យរលាយបដិមាក្រមួនហូរចេញមកក្រៅ ហើយរក្សាទីទំនេរសម្រាប់សិតស្ពាន់បញ្ចូលបានជាបដិមាព្រះនាងឥន្ទ្រទេវីអំពីស្ពាន់។ នៅពេលដុត ឈ្នុលក្រមួនដែលបានបណ្តុះឡើងក៏ត្រូវរលាយ ហើយក្លាយជារន្ធសម្រាប់សិតស្ពាន់ចូល។*

*ការដុតពុម្ពទាមទារឱ្យភ្លើងមានកម្តៅខ្លាំងនិងធំល្អ ទើបអាចរំលាយបដិមាក្រមួនដែលស្រោបដោយម្នាងសិលានិងដីលាយអង្កាមបាន។ ប្រសិនបើភ្លើងដុតពុម្ពមិនមានកម្តៅល្អគ្រប់គ្រាន់ទេ នោះគឺអាចមានបញ្ហានៅពេលសិតស្ពាន់ ហើយរូបក៏មិនល្អដែរ។ ហេតុនេះ ដើម្បីដុតពុម្ព គេបានតម្រៀបពុម្ពតម្កល់លើឥដ្ឋ ហើយរៀបឧសនៅខាងក្រោមនិងនៅជុំវិញពុម្ព។ ជាងនេះទៀត នៅពេលដុត គេត្រូវយកស័ង្កសីមកព័ទ្ធជុំវិញនិងគ្របពីលើថែមទៀតដើម្បីឱ្យភ្លើងរក្សាកម្តៅធំល្អ។*

*ជាបច្ចេកទេសក្នុងការពិនិត្យមើលពុម្ពឆ្អិនឬនៅ គឺគេមើលតាមឈ្នុលក្រមួនដែលគេបានបណ្តុះ។ ប្រសិនបើ រន្ធផើយឈ្នុលនៅហុយផ្សែង នោះគឺក្រមួននៅមិនទាន់រលាយអស់ទេ។ ហេតុនេះ នៅពេលរន្ធផើយឈ្នុលឈប់មានផ្សែង ទើបក្រមួនរលាយអស់ ហើយគេសន្មតថា ពុម្ពឆ្អិន។*

*បន្ទាប់ពីបានដុតពុម្ពឆ្អិនហើយ គេត្រូវរក្សាពុម្ពនោះឱ្យនៅមានកម្តៅរហូតដល់ពេលសិត ព្រោះបើពុម្ពត្រជាក់ នោះនឹងធ្វើឱ្យស្ពាន់ធាប់កកនៅពេលសិតស្ពាន់ចូល មិនបានហូរជ្រាបចូលដល់កន្ទុកកន្ទៀតនៃរូប ដែលធ្វើឱ្យបដិមាស្ពាន់ចេញមកមិនស្អាតស្មើសាច់ល្អ។*



ការចាប់ផ្ដើមដុតពុម្ពបដិមាព្រះនាងឥន្ទ្រទេវី



ការបៃភ្លើងដុតពុម្ពបដិមាព្រះនាងឥន្ទ្រទេវីនៅពេលយប់



រន្ធផើយឈ្នួលសម្រាប់សិតស្ពាន់ចូល



សកម្មភាពបៀកបិទពុម្ពដែលប្រេះដោយការដុត

**៥- ដំណាក់កាលសិតបដិមា**

នៅវេលាព្រឹកថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៩ រាជបណ្ឌិត្យសភាកម្ពុជាបានរៀបចំពិធីសិតបដិមាព្រះនាងឥន្ទ្រទេវី អំពីស្ពាន់ ក្រោមអធិបតីភាពនៃលោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន។ ពិធីសិតរូបនេះបានប្រព្រឹត្តទៅយ៉ាងអធិកអធម ជាលក្ខណៈប្រពៃណីជាតិ ក្រោមជំនួយឧបត្ថម្ភពីលោកជំទាវឧកញ៉ាកិត្តិបណ្ឌិត សៀង ចាន់ហេង នាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍។

ជាប្រពៃណី នៅដំណាក់កាលសិតបដិមាព្រះនាងឥន្ទ្រទេវី ជាងស្មិតបានធ្វើកិច្ចសែនព្រេនអុជធូប ដើម្បីបួងសួងសុំឱ្យដំណើរការសិតបដិមាប្រព្រឹត្តទៅដោយជោគជ័យ សិតរូបបានល្អ មិនខូច មិនស្អុយ។



ពិធីសិតបដិមាព្រះនាងឥន្ទ្រទេវី



លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ចូលរួមជាអធិបតីក្នុងពិធីសិតបដិមាព្រះនាងឥន្ទ្រទេវី



លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន និង ឯកឧត្តមបណ្ឌិតសភាចារ្យសុខ ទូច ដុតទៀនក្នុងពិធីសិតបដិមាព្រះនាងឥន្ទ្រទេវី



លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ដាក់កាក់ស្ពាន់ចូលក្នុងបាវសម្រាប់ស្ងំរំលាយ



ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដាក់កាក់ស្ពាន់ចូលក្នុងបាវ ក្នុងពិធីសិតបដិមាព្រះនាងឥន្ទ្រទេវី



លោកជំទាវឧកញ៉ាកិត្តិបណ្ឌិត សៀង ចាន់ហេង ដាក់កាក់ស្ពាន់ចូលក្នុងបាវក្នុងពិធីសិតបដិមាព្រះនាងឥន្ទ្រទេវី

ក្នុងដំណើរការស្ងស្ពាន់សិតបដិមាព្រះនាងឥន្ទ្រទេវី ជាងស្មិតបានប្រើឧបករណ៍និងវត្ថុធាតុដូចជា ឡដុតស្ពាន់បាវ (វត្ថុដាក់ស្ពាន់ដុតក្នុងឡ) ឧបករណ៍សម្រាប់ចាប់លើកបាវ (តង្កៀប) ម៉ូទ័រខ្យល់ និង ប្រេងម៉ាស៊ីន ជាដើម ។ ជាទូទៅ គេអាចស្ងស្ពាន់ដោយប្រើឧសឬធ្យូង តែការស្ងស្ពាន់ដោយប្រើអុសឬធ្យូងត្រូវចំណាយពេលយូរ ពោលគឺ

អាចចំណាយពេលប្រមាណពី ៥ម៉ោង ទៅ ៦ម៉ោង ឯការស្លស្ពាន់ដោយការប្រើចំហេះប្រេងម៉ាស៊ីនអាចចំណាយពេលត្រឹមតែពី ២ម៉ោង ទៅ ៣ម៉ោងប៉ុណ្ណោះ។

ជាងស្មិតបានប្រើបាវចំនួនបីសម្រាប់ដាក់ស្ពាន់ស្លនិងសម្រាប់សិតស្ពាន់ (សម្រាប់ស្លក្នុងឡចំនួនបីដែរ) ដែលបាវនីមួយៗអាចដាក់ស្ពាន់បានចំណុះ ៧០គីឡូក្រាម។ ជារួម ជាងស្មិតបានប្រើស្ពាន់អស់ប្រមាណ ២០០គីឡូក្រាមសម្រាប់សិតបដិមាព្រះនាងឥន្ទ្រទេវីទាំងមូល ហើយបានចំណាយអស់រយៈពេលប្រមាណ ៣ម៉ោង[3]។



បាវស្លស្ពាន់និងឧបករណ៍លើកសែងបាវ (តង្កៀប) ដើម្បីសិតស្ពាន់



តង្កៀបប្រើជាឧបករណ៍សម្រាប់ចាប់លើកបាវដាក់ចូលឡឬលើកចេញពីឡ




សកម្មភាពស្លកាក់ស្ពាន់

[3] ព្រាប សោភ័ណ ស្ថាបត្យករអគារឥន្ទ្រទេវីនិងជាអ្នកជំនាញខាងសំណង់បុរាណ។ (សម្ភាសថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩)។

បន្ទាប់ពីស្ងស្ពាន់រលាយ (រលាយក្នុងបាវ) ហើយ ជាងស្មិតសិតស្ពាន់បញ្ចូលក្នុងពុម្ពទាំងឡាយតាមរន្ធឈ្នុល រហូតស្ពាន់បានហូរចូលជ្រួតជ្រាបសព្វអស់ក្នុងពុម្ព។ ចំពោះពុម្ពធំៗដែលមានរន្ធឈ្នុលច្រើន (មាននៅផ្នែកខាងក្រោមនិងផ្នែកខាងលើនៃពុម្ព) ជាងស្មិតត្រូវសិតស្ពាន់ចូលទៅតាមរន្ធឈ្នុលនៅផ្នែកខាងក្រោមជាមុន។ នៅពេលសិតស្ពាន់ចូលពេញដល់រន្ធឈ្នុលនៅផ្នែកខាងក្រោមនេះហើយ គេត្រូវយកដីបិទរន្ធឈ្នុលនោះ រួចទើបបន្តសិតស្ពាន់ចូលពុម្ពតាមរន្ធឈ្នុលនៅផ្នែកខាងលើនោះជាបន្តបន្ទាប់ទៀត។




សកម្មភាពសិតស្ពាន់ចូលពុម្ពតាមរន្ធឈ្នុល



ការបិទរន្ធឈ្នុលនៅផ្នែកខាងក្រោម ដើម្បីការពារស្ពាន់ហូរចេញនៅពេលសិតស្ពាន់ចូលពុម្ពបន្តទៀត

### ៦- ដំណាក់កាលផ្តុំសម្រេច

បន្ទាប់ពីបានសិតស្ពាន់ចូលពុម្ពរួចហើយ គេបានរក្សាទុកឱ្យស្ពាន់ត្រជាក់កករឹងសិនមុននឹងគេវាយបំបែកពុម្ពទាំងនោះ ដើម្បីបានបដិមាអំពីស្ពាន់។ ក្រោយពេលវាយបំបែកពុម្ពនិងបានបដិមាហើយ ជាងស្មិតត្រូវសម្អាតផ្នែកទាំងអស់នៃបដិមាស្ពាន់នោះ ដោយការសម្អាតម្នាងសិលានៅជាប់រូប (ទាំងខាងក្នុង[4] ទាំងខាងក្រៅ) កាត់ឈ្នុលស្ពាន់ចេញ ផ្សារភ្ជិតស្នាមប្រេះនៅផ្នែកព្រះសិរនិងសំពត់ ហើយខាត់រំលីងឱ្យស្អាត រួចទើបផ្តុំផ្នែកទាំងអស់នៃបដិមានោះបញ្ចូលគ្នា។ គេត្រូវពិនិត្យនិងសម្អាតបដិមានេះជាច្រើនដំណាក់កាលរហូតដល់ផ្នែកទាំងអស់នៃបដិមាមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងស្អាតល្អ។

[4] នៅផ្នែកខ្លះដែលគេពិបាកយកម្នាងសិលាចេញ គេរក្សាវាទុកនៅក្នុងនោះ ហើយនៅផ្នែកខ្លះគឺមិនមានម្នាងសិលានៅខាងក្នុងទេ ដោយគេសិតជាស្ពាន់តែម្តង។



សកម្មភាពវាយបំបែកពុម្ពនៅផ្នែកខាងក្រៅ



បដិមាស្ពាន់បានពីការសិតភ្លាមៗ



សកម្មភាពដាប់យកដីម្នាងសិលាចេញពីផ្នែកខាងក្នុងបដិមា



សកម្មភាពផ្សារភ្ជិតទីប្រេះស្រាំ



ផ្នែកនៃដៃទាំងពីរ



ផ្នែកនៃផ្កាឈូក



សកម្មភាពផ្សារផ្គុំបដិមា (រូបភាពពីមុខ)



សកម្មភាពផ្សារផ្គុំបដិមា (រូបភាពពីក្រោយ)



បដិមាព្រះនាងឥន្ទ្រទេវីក្រោយផ្គុំនិងសម្អាតរួច (រូបភាពពីមុខ)



បដិមាព្រះនាងឥន្ទ្រទេវីក្រោយផ្គុំនិងសម្អាតរួច (រូបភាពពីក្រោយ)

បន្ទាប់ពីបានផ្គុំផ្នែកទាំងឡាយនៃបដិមាចូលគ្នា និងសម្អាតរួចរាល់ហើយ ជាងស្មិតបានដាក់ពណ៌ (បញ្ចូលពណ៌) លើបដិមាទោលព្រះនាងឥន្ទ្រទេវីជាពណ៌សំរិទ្ធដោយជាងស្មិតបាញ់ភ្លើងហើយញីស្ពាន់ជ័របន្សុំជាមួយពណ៌ដើម។ ការដាក់ពណ៌បដិមា គឺដើម្បីរក្សាពណ៌ឱ្យនៅបានយូរអង្វែង។ ប្រសិនបើមិនដាក់ពណ៌ទេ នោះពណ៌ស្ពាន់នៃបដិមានឹងឆាប់ប្រែប្រួល ដោយសារការត្រូវទឹកនិងខ្យល់ច្រើន ហើយពណ៌នោះនឹងប្រែទៅជាពណ៌ខ្មៅៗដោយកន្លែងនិងមិនស្មើគ្នា (ធ្វូកៗដោយកន្លែង) ដែលនាំឱ្យមិនស្អាត។

ពណ៌បែបសំរិទ្ធជាពណ៌ដែលធ្លាប់បានប្រើប្រាស់យូរមកហើយ ពិសេសគេប្រើលើបដិមាប្រភេទលង្ហិនសម្រាប់គោរពបូជា ដែលធ្វើឱ្យបដិមាមើលទៅកាន់តែមានទម្ងន់និងមានតម្លៃ។ ហេតុនេះ ការប្រើពណ៌សំរិទ្ធលើបដិមាព្រះនាងឥន្ទ្រទេវី គឺជារឿងស័ក្តិសមត្រូវនឹងតម្លៃនៃបដិមានេះ។ ម្យ៉ាងទៀត ការជ្រើសរើសពណ៌នេះ គឺសមនឹងសំណង់បុស្បុកមានពណ៌បែបថ្មភក់ ហើយក៏ស័ក្តិសមនឹងពណ៌អគារឥន្ទ្រទេវីផងដែរ។



បដិមាព្រះនាងឥន្ទ្រទេវីពីខាងមុខនិងពីខាងក្រោយបន្ទាប់ពីដាក់ពណ៌រួច

**បដិមាទោលព្រះនាងឥន្ទ្រទេវីនិងគ្រឿងតុបតែងលម្អ**

បដិមាព្រះនាងឥន្ទ្រទេវីមានភក្រ្តទម្រង់ពងក្រពើ មានទឹកព្រះភក្រ្តញញឹម ស្រស់ទ្រទន់ ដៃខាងស្តាំកាន់កម្រងផ្កាទម្លាក់ចុះ និងដៃខាងឆ្វេងកាន់ផ្កាឈូកមួយមែកបែកចេញជាបីគឺមានផ្កាឈូកក្រពុំ ផ្កាឈូករីកចេញផ្លែ

និងស្ទឹក ហើយព័ទ្ធទៅខាងក្រោយខ្នងរួចទម្លាក់ចុះមកចំហៀងខាងស្តាំ។ បដិមាព្រះនាងឥន្ទ្រទេវីទ្រដោយទម្រផ្កាឈូកមានសត្វក្រពើព័ទ្ធខាងមុខ។

គ្រឿងតុបតែងលម្អនៃបដិមាព្រះនាងឥន្ទ្រទេវី មានជាអាទិ៍ មកុដរាងក្រពុំឈូកដែលរចនាលម្អដោយក្បួង (ផ្កាមូលៗ) ក្នុងទម្រង់ក្បាច់ចក។ ក្បាំងមកុដ មានចង្វាយក្បាច់ចំនួនបួនចង្វាយ ដោយចង្វាយក្បាច់ទីមួយ (ពីក្រោមទៅលើ) រចនាជាក្បាច់ពងត្រី ចង្វាយក្បាច់ទីពីរ រចនាជាក្បាច់ត្របកឈូកខ្វៃលាតពីរជាន់ ចង្វាយក្បាច់ទីបី រចនាជាក្បាច់ពងត្រី និងចង្វាយក្បាច់ទីបួន រចនាជាក្បាច់ត្របកឈូកលាតពីរជាន់។ នៅកណ្តាលក្បាំងមកុដមានរចនាលម្អដោយក្បាច់ត្របកឈូកបំបែកជារាងសន្ទឹកបី។ នៅទាំងពីរខាងនៃមកុដ មានលម្អបន្ថែមដោយស្នៀតរំយោលពីរៗ។

បដិមាព្រះនាងឥន្ទ្រទេវីពាក់ក្រវិលកងដែលត្រចៀកម្ខាងៗមានកងចំនួនប្រាំ។ កងដៃ ស្នាប់ដៃ(កងដើមដៃ) រចនាដោយក្បាច់យ៉ាងល្អវិចិត្រ ហើយពាក់កងជើងម្ខាងចំនួនពីរកង។ ក្រៅពីនេះ បដិមានេះមានពាក់សង្វារព័ន្ធ (ឆៀងខ្លួង) ដែលមានរំលេចដោយក្បាច់រចនាមួយចំនួនដូចជា ក្បាច់ពងត្រី ក្បាច់ត្របកឈូកបំបែក និងក្បាច់ផ្កាច័នចំនួនពីរនៅផ្នែកខាងមុខ។ ចំណែកឯខ្សែក្រវាត់ គឺរចនាដោយក្បាច់ផ្កាច័នមួយធំរំលេចនៅខាងមុខ។ ខ្សែក្រវាត់មានចង្វាយក្បាច់រចនាជាក្បាច់ពងត្រីពីរខ្សែដែលនៅអមសងខាងដោយក្បាច់ផ្កាខណ្ឌដោយខ្សែជុំវិញ។ ខ្សែក្រវាត់នេះ មានរំលេចជាសន្ទឹករំយោលទម្លាក់ចុះព័ទ្ធជុំវិញ។

សំពត់បដិមាព្រះនាងមានរាងកន្ទុយត្រីដែលមានរចនាលម្អដោយផ្កា ហើយផ្ទាំងនៅផ្នែកខាងមុខមានរចនាលម្អក្បាច់ជាចង្វាយៗដែលមាន ចង្វាយក្បាច់ពងត្រី (មានក្បាច់ពងត្រីតូច ក្បាច់ពងត្រីធំ) ចង្វាយក្បាច់ច័ក្កច័នចង្វាយក្បាច់រាងត្របកឈូកផ្កាប់និងត្របកឈូកផ្ងារ។ នៅជរសំពត់ទទឹងខាងក្រោម មានរចនាលម្អដោយក្បាច់ត្របកឈូកលាត (ខាងលើ) និង ក្បាច់ពងត្រី (ខាងក្រោម)។ ជើងទម្របដិមាព្រះនាងឥន្ទ្រទេវី គឺជាផ្កាឈូកដែលផ្ទៃខាងលើធ្លាក់ជាគ្រាប់ឈូកក្នុងទម្រង់ក្បាច់ពងត្រី ហើយផ្ទៃជុំវិញរចនាជាក្បាច់ត្របកឈូកលាតផ្កាប់ ត្របកឈូកលាតផ្ងារ ក្បាច់កេសរឈូកដែលមានសត្វក្រពើនៅព័ទ្ធពីក្រោម។





រូបចម្លាក់ ព្រះនាងឥន្ទ្រទេវី នៅប្រាសាទព្រះខ័ន (សៀមរាបអង្គរ)

## **ពិធីអភិសេកបដិមាព្រះនាងឥន្ទ្រទេវី**

*នៅថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ៩ព្រឹក រាជបណ្ឌិត្យសភាកម្ពុជាបានរៀបចំពិធីសូត្រមន្តចម្រើនព្រះបរិត្ត និង ប្រោះព្រំលើករាសីសំណង់បុស្បុកនិង អភិសេកបដិមាព្រះនាងឥន្ទ្រទេវីនិងអគារឥន្ទ្រទេវី ក្រោមវត្តមានរបស់ឯកឧត្តមបណ្ឌិត្យសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងលោកជំទាវកិត្តិបណ្ឌិតឧកញ៉ា សៀង ចាន់ហេង នាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីនៃរាជបណ្ឌិត្យសភាកម្ពុជាផងដែរ។*

*នៅថ្ងៃប្រារព្ធពិធីនេះដែរ មានហេតុភេទកើតឡើងគួរឱ្យចាប់អារម្មណ៍ដោយតាំងពីដំណើរការចាប់ផ្តើមកម្មវិធីរហូតបញ្ចប់ មេឃស្រទំុត្រជាក់ល្អ ដែលផ្តល់នូវបរិយាកាសល្អដល់អ្នកចូលរួមក្នុងពីធី។ ប៉ុន្តែក្រោយពេលពិធីនេះបានបញ្ចប់ មេឃក៏ចាប់ផ្តើមបញ្ចេញពន្លឺភ្វាម ដែលជាហេតុការណ៍ធ្វើឱ្យអ្នកចូលរួមទាំងឡាយមានការចាប់អារម្មណ៍ចំពោះបដិមាទោលព្រះនាងឥន្ទ្រទេវីនេះ។*



*ពិធីអភិសេកបដិមាព្រះនាងឥន្ទ្រទេវី*



*ពិធីសូត្រមន្តចម្រើនព្រះបរិត្ត និង ប្រោះព្រំលើករាសីសំណង់បុស្បុកបដិមាព្រះនាងឥន្ទ្រទេវី*
*(ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច និង លោកជំទាវ សៀង ចាន់ហេង)*

*ការកសាងបដិមាទោលព្រះនាងឥន្ទ្រទេវីគឺបានធ្វើឡើងដោយមានការយកចិត្តទុកដាក់ និង ទទួលខុសត្រូវខ្ពស់ ទាំងផ្នែកវិទ្យាសាស្ត្រ ទាំងផ្នែកបច្ចេកទេស។ បដិមានេះ គឺចម្លងតាមរូបចម្លាក់ដ៏ប្រណិតមួយនៅជញ្ជាំងនៃប្រសាទព្រះខ័ន តាមរយៈការសិក្សាស្រាវជ្រាវនិងសិក្ខាសាលាតុមូលមួយដែលមានការចូលរួមពីអ្នកស្រាវជ្រាវនិងអ្នកជំនាញជាតិនិងបរទេស។ លើសពីនេះទៀត រាល់ដំណាក់កាលនៃការកសាងបដិមានេះ គឺតែងតែមានការចុះពិនិត្យផ្ទៀងផ្ទាត់ពីក្រុមស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា ដោយពិនិត្យជាពិសេសទៅលើសុក្រឹតភាពនៃការចម្លងពីរូបចម្លាក់ដើម។ គ្រឿងតុបតែងលម្អជាអាទិ៍ មកុដ សំពត់ សង្វារព័ន្ធ និង ទម្រផ្កាឈូកដែលមានក្រពើព័ទ្ធជាដើម សុទ្ធសឹងបានចម្លងតាមរូបចម្លាក់ដើម។*

*ហេតុនេះ បដិមាទោលព្រះនាងឥន្ទ្រទេវីនៅរាជបណ្ឌិត្យសភាកម្ពុជាគឺជាបដិមាទោលដំបូងគេនៅក្នុងប្រវត្តិសាស្ត្រដែលអាចជាគំរូសម្រាប់កសាងចម្លង និង រក្សាតម្កល់នៅទីកន្លែងផ្សេងទៀត។*

## ឯកសារពិគ្រោះ

*ឯកសារ*

- ង៉ិន ផល្ញីកា ៖ *ត្រៃក្សត្រ*  ភ្នំពេញ ឆ្នាំ២០១២
- លី ធាមតេង ៖ *កំណត់ហេតុរបស់ជីវតាក្វាន់អំពីប្រពៃណីនៃអ្នកស្រុកចេនឡា* ភ្នំពេញ ឆ្នាំ១៩៧៣

*កិច្ចសម្ភាស*

- *ព្រាប សោភ័ណ អ្នកជំនាញខាងសំណង់បុរាណ (សម្ភាសថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩)*
- *សុផុន សំខាន់ ព្រឹទ្ធបុរសរងមហាវិទ្យាល័យសូនរូប ជំនាញចម្លាក់ (សម្ភាសថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩)*
- *សុខ ពិសិដ្ឋ  ជាងស្មិត (សម្ភាសថ្ងៃទី០៧ កញ្ញា ឆ្នាំ២០១៩)*